**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
Ministry of Agriculture Forestry and Fisheries
**គម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជា**
Cambodia Agricultural Sector Diversification Project
World Bank Loan No .IDA Credit 6366-KH

**អង្គភាពសម្របសម្រួលគម្រោង**
លេខ: ០០៥..........CASDP/MAFF

ថ្ងៃសុក្រ ១០ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០២១

## ជម្រាបជូន
## លោកប្រធានគ្នាក់ងារអនុវត្តគម្រោងថ្នាក់ខេត្តពាក់ព័ន្ធ
## នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា

**កម្មវត្ថុ** ៖ ស្តីពីការផ្សព្វផ្សាយបន្តនូវសេចក្តីជូនដំណឹងស្តីពីការផ្តល់ហិរញ្ញប្បទានបន្ថែមទុនវិនិយោគ។
**ជូនភ្ជាប់**៖ សេចក្តីជូនដំណឹងស្តីពីការផ្តល់ហិរញ្ញប្បទានបន្ថែមទុនវិនិយោគ........................................ចំនួន ១ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាប លោកប្រធាន ជ្រាបថា គម្រោងពិពិធកម្មកសិកម្មកម្ពុជានឹងធ្វើការជ្រើសរើសសហគមន៍កសិកម្ម ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យមដែលកំពុងប្រតិបត្តិការអាជីវកម្មពាក់ព័ន្ធវិស័យកសិកម្ម ក្នុងការផ្តល់ជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (Matching Grant Facility-MGF)ចាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ២០២១ ដល់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២១ខាងមុខនេះ ដូចមានរៀបរាប់ក្នុងសេចក្តីជូនដំណឹងភ្ជាប់មកជាមួយ។ ចំពោះមុខ ដើម្បីឲ្យដំណើរការអនុវត្តទទួលបានជោគជ័យតាមការរំពឹងទុកនោះ អង្គភាពសម្របសម្រួលគម្រោង ស្នើ លោកប្រធាន ជួយជំរុញ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងខាងលើបន្តដល់អ្នកពាក់ព័ន្ធនៅក្នុងបណ្តាឃុំ និងស្រុកនៃខេត្តនីមួយៗឲ្យបានទូលំទូលាយ។

អាស្រ័យហេតុនេះ សូម លោកប្រធាន ជ្រាប និងចាត់ចែងអនុវត្ត តាមការគួរ។

សូម លោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**អគ្គលេខាធិការរង**
**និងនាយកគម្រោង**

សរ ជីវា

**ចម្លងជូន៖**
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ
"ដើម្បីជ្រាប"
-ឯកសារ កាលប្បវត្តិ

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការទទួលសំណើសុំជំនួយហិរញ្ញប្បទានឥតសំណង**
**បំពេញបន្ថែមទុនវិនិយោគ**( Matching Grant Facility )

គម្រោងពិពិធកម្មកសិកម្មកម្ពុជា(Cambodia Agricultural Sector Diversification Project) ដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម ក្រោមហិរញ្ញប្បទានពីធនាគារពិភពលោក (World Bank) និងរាជរដ្ឋាភិបាលកម្ពុជា សូមជូនដំណឹងដល់សាធារណជនទាំងអស់មេត្តាជ្រាបថា គម្រោងនឹងធ្វើការផ្តល់ជំនួយហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ (Matching Grant Facility-MGF) ដល់សហគមន៍កសិកម្ម ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យម ដែលកំពុងប្រតិបត្តិការអាជីវកម្មពាក់ព័ន្ធវិស័យកសិកម្ម នៅទូទាំងខេត្តរតនគិរី មណ្ឌលគិរី និងខេត្តក្រចេះ។ ដើម្បីទទួលបានជំនួយហិរញ្ញប្បទាន និងឥណទានខាងលើ សហគមន៍កសិកម្ម ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យម ត្រូវដាក់សំណើពិពិធកម្មកសិកម្ម និងសំណើធុរកិច្ចស្របតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

- ម្ចាស់សំណើត្រូវស្ថិតនៅក្នុងតំបន់ប្រតិបត្តិការរបស់គម្រោងពិពិធកម្មកសិកម្មកម្ពុជា
- ម្ចាស់សំណើត្រូវមានសកម្មភាពធុរកិច្ចរបស់ខ្លួនក្នុងផលិតកម្មកសិកម្ម និងការកែច្នៃ (កម្រិតបឋម ពាក់កណ្តាលសម្រេច និងសម្រេច)
- ម្ចាស់សំណើត្រូវមានការទទួលស្គាល់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ម្ចាស់សំណើមានចំណាប់អារម្មណ៍ពិតប្រាកដក្នុងការចូលរួមអនុវត្តក្នុងខ្សែច្រវាក់តម្លៃក្រៅពីផលិតកម្មស្រូវ
- ម្ចាស់សំណើកំពុងប្រតិបត្តិការក្នុងច្រវាក់ផ្គត់ផ្គង់ក្រៅពីដំណាំស្រូវ ឬមានចំណាប់អារម្មណ៍យ៉ាងជាក់ច្បាស់ ដើម្បីចូលរួមក្នុងច្រវាក់តម្លៃផលិតកម្ម ដែលមិនផ្តោតលើដំណាំស្រូវ ថ្នាំជក់ និងគ្រឿងស្រវឹងក្នុងខេត្តគោលដៅ
- សហគ្រាសខ្នាតតូចនិងមធ្យម ត្រូវជាសហគ្រាសឯកជន ១០០% មាននិយោជិតមិនលើសពី ១០០ នាក់ និងមានទ្រព្យសម្បត្តិហិរញ្ញវត្ថុ (មិនរាប់បញ្ចូលដី) ក្រោម ៥០០.០០០ ដុល្លារ
- ត្រូវតែជាអាជីវកម្មដែលបានចុះបញ្ជី ឬសមាគមផលិតកម្មដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ ដោយមានការបង់ពន្ធគិតរហូតដល់ពេលបច្ចុប្បន្ន ឬត្រូវបានលើកលែងពីការបង់ពន្ធស្របតាមច្បាប់។ ក្រុមផលិតកម្ម និងសហគ្រាសខ្នាតតូចនិងមធ្យម ដែលទើបត្រូវបានបង្កើតឡើងកាលពីពេលថ្មីៗនេះ ក៏មានសិទ្ធិចូលរួមផងដែរ
- យល់ព្រមអនុវត្តទៅតាមលក្ខខណ្ឌផ្សេងៗទៀត ដែលតម្រូវដោយគម្រោង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រុមផលិត សហគមន៍កសិកម្ម កសិ-ធុរកិច្ចខ្នាតតូច និងមធ្យម (អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អ្នកទិញ អ្នកកែច្នៃ) ក្នុងគោលដៅគម្រោងខេត្តរតនគិរី មណ្ឌលគិរី និងខេត្តក្រចេះដែលមានចំណាប់អារម្មណ៍សូមទំនាក់ទំនងផ្ទាល់មកក្រុមការងារផ្តល់សេវាគាំទ្របច្ចេកទេសគម្រោងពិពិធកម្មកសិកម្ម ដើម្បីបំពេញទម្រង់សំណើពិពិធកម្មកសិកម្ម និងសំណើធុរកិច្ច និងផ្ញើសំណើជាភាសាខ្មែរ ដាក់ក្នុងស្រោមសំបុត្របិទជិត ចំនួន៣ច្បាប់ និងចម្លងឌីជីថល (USB memory stick in write-protected pdf-format) មកកាន់អង្គភាពសម្របសម្រួលគម្រោង នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាន់ផ្ទាល់ដីនៃនាយកដ្ឋាន

សហប្រតិបត្តិការអន្តរជាតិ ដែលមានអាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៧ ខែមិនា ឆ្នាំ២០២១ វេលាម៉ោង១៧:០០នាទីល្ងាច។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

**ក. ក្រុមការងារគម្រោងពិពិធកម្មកសិកម្មកម្ពុជាទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- លោកបណ្ឌិត **សរ ចិត្រា** នាយកគម្រោង លេខទូរស័ព្ទ ០៧៧ ៥៦៣ ៣៧៧
- លោក **ហុក គីមធួន** ប្រធានគ្រប់គ្រងគម្រោង លេខទូរស័ព្ទ ០១២ ៤៤៩ ៦៩៣

អ៊ីម៉ែល: casdp@maff.gov.kh

គេហទំព័រ: https://casdp.maff.gov.kh

**ខ. ក្រុមការងារផ្តល់សេវាគាំទ្របច្ចេកទេស** (Technical Service Provider) ដើម្បីទទួលបាននូវទម្រង់សំណើសុំ។

តំបន់២៖ ខេត្តព្រះវិហារ រតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងខេត្តត្បូងឃ្មុំ លេខទូរស័ព្ទ៖ -០១២ ៧៩៧ ៣៧៣

-០៩៧ ៤៦៣ ៣៦១៣

**សូមអរគុណ**!!!